**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាភូមិន្ទរដ្ឋបាល**

**នាយកដ្ឋានបណ្តុះបណ្តាលដំបូង**

**សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១៣**

# កិច្ចការស្រាវជ្រាវ

# ស្តីពី

# គម្រោងកសាងបណ្ណាល័យសហគមន៍ព្រៃកង្វែ

មុខវិជ្ជា ៖ **ការគ្រប់គ្រងគម្រោង**

គ្រូឧទ្ទេសនាម ៖ **បណ្ឌិត ព្រុំ ទេវី**

រៀបចំដោយ ៖ **សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១៣**

- លោក យឿន ចើត
- លោក ប៊ិន ម៉េងលាង
- លោក វ៉ុន សីហៈ
- លោក រតនា តារា
- លោកស្រី យ៉ាន ដារីយ៉ា
- កញ្ញា ជួន អមរា

**ឆ្នាំសិក្សា ២០២៥-២០២៧**

# មាតិកា


I. **សារាងគម្រោង** ..... 1

II.**ការរៀបចំផែនការគម្រោង** ..... 1

១.គោលបំណង ..... 1

៣.សកម្មភាព ..... 2

៤.ថវិកាសមិទ្ធកម្ម ..... 2

៥.អ្នកទទួលខុសត្រូវ ..... 3

៦.សូចនាករ ..... 4

៧.មធ្យោបាយផ្ទៀងផ្ទាត់ ..... 5

៨.ហានិភ័យ ..... 6

III. **ដំណើរការគម្រោង** ..... *7*

១- ការកំណត់ប្រភពថវិកា ..... 7

២- ការជ្រើសរើសធនធានមនុស្ស ..... 7

៣- ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ..... 7

៤- ការប្រើប្រាស់ផែនការពេលវេលា ..... 9

៥- ការប្រើប្រាស់ធនធានរបស់គម្រោង ..... 11

៦- ការតាមដាន ការវាយតម្លៃ និងត្រួតពិនិត្យគម្រោង ..... 12

៦-១. ការតាមដាន ..... 12

៦-២. ការវាយតម្លៃ ..... 12

៦-៦. ការតាមដានបន្ត ..... 12

៧- ការបញ្ចប់គម្រោង ..... 12

IV. **ការវិភាគ** SWOT ..... 13

V. **សេចក្តីសន្និដ្ឋាន** ..... 13

## I. សាវតារគម្រោង

កម្ពុជាជាប្រទេសដែលធ្លាប់ឆ្លងកាត់នូវសង្គ្រាមស៊ីវិលដែលធ្វើឱ្យប៉ះពាល់គ្រប់វិស័យផ្លូវថ្នល់ ហេដ្ឋារចនាសម្ព័ន្ធ អ្វីដែលគួរឱ្យកត់សម្គាល់ក្នុងសង្គ្រាមនេះបានធ្វើឱ្យប្រជាពលរដ្ឋដែលមានចំណេះដឹង និងមានសមត្ថភាពជាច្រើនបាត់បង់អាយុជីវិត ហើយមានខ្លះទៀតបានចាកចេញទៅរស់នៅក្រៅប្រទេសដើម្បីរក្សាជីវិតផងដែរ។ដោយសារតែប្រទេសយើងធ្លាប់ឆ្លងបានកាត់សង្គ្រាមនេះហើយ ដែលជាមូលហេតុធ្វើឱ្យប្រទេសយើងខ្វះខាតធនធានមនុស្សដែលពោរពេញដោយចំណេះដឹង និងសមត្ថភាព បានប្រែក្លាយពីប្រទេសដែលមានការរីកចំរើនគ្រប់វិស័យមកជាប្រទេសមានវិបត្តិទៅវិញ។

បើសង្កេតមើលស្ថានភាពបច្ចុប្បន្ន បន្ទាប់ពីប្រទេសយើងទទួលបានសន្តិភាពពេញលេញ គឺមានការរីកចម្រើនគ្រប់វិស័យយ៉ាងឆាប់រហ័ស ពីព្រោះថាពេលបច្ចុប្បន្ននេះរាជរដ្ឋាភិបាលបាននឹងកំពុងអនុវត្ត នូវយុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទី១ ក្នុងនោះបញ្ចកោណទី១ ដោយបានកំណត់យកការអភិវឌ្ឍធនធានមនុស្សដើម្បីជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងជានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ដូច្នេះដើម្បីចូលរួមអនុវត្ត និងរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្រ្តនេះឱ្យទទួលបានប្រសិទ្ធិភាព ក្រុមរបស់យើងខ្ញុំបានបង្កើតគម្រោងមួយគឺការសាងសង់បណ្ណាល័យសហគមន៍ ដែលស្ថិតនៅភូមិព្រៃកជ្រៃ ឃុំព្រៃកជ្រៃ ស្រុកកោះធំ ខេត្តកណ្តាល ដើម្បីជាផ្នែកមួយក្នុងការគាំទ្រដល់ការអភិវឌ្ឍចំណេះដឹង ដើម្បីធ្វើជាទុនក្នុងការអភិវឌ្ឍប្រទេស និងបណ្តុះស្មារតីឱ្យស្រលាញ់ក្នុងការអានសៀវភៅពីព្រោះថាការអានសៀវភៅបានផ្តល់នូវចំណេះដឹង គំនិតថ្មីៗ។

បច្ចុប្បន្ននេះ នៅភូមិព្រៃកជ្រៃគឺជាសហគមន៍មួយដែលស្ថិតនៅភូមិសាស្រ្តនៅឆ្ងាយពីទីប្រជុំជន ពិបាកក្នុងការធ្វើដំណើរ ហើយក្នុងការស្វែងរកទិញសៀវភៅ ឬក្នុងការធ្វើដំណើរនោះទៀតសោតគឺត្រូវចំណាយពេលវេលាច្រើន ទើបក្រុមយើងខ្ញុំបានបង្កើតនូវគម្រោងសាងសង់បណ្ណាល័យសហគមន៍ ហើយចំពោះប្រភពថវិកាបានមកពីជំនួយរបស់ជីវិតថ្លៃថ្នូ (LWD) មន្ទីរអប់រំ យុវជន និងកីឡា និងប្រជាសហគមន៍។ ជាពិសេសទៀតនោះ មានការចូលរួមសហការពីអាជ្ញាធរមូលដ្ឋាននៅ ក្នុងសហគមន៍ផងដែរ ដោយបានផ្តល់នូវទីតាំងមួយដែលសមរម្យក្នុងការសាងសង់ ដើម្បីបម្រើជាប្រយោជន៍ដល់សិស្សានុសិស្ស ក៏ដូចជាសាធារណៈជនទូទៅផងដែរ។

### ទីតាំង៖ ភូមិព្រៃកជ្រៃ ឃុំព្រៃកជ្រៃ ស្រុកកោះធំ ខេត្តកណ្តាល

ភូមិព្រៃកជ្រៃស្ថិតនៅចម្ងាយ ៨គីឡូម៉ែត្រ ពីឃុំព្រៃកជ្រៃ ហើយស្ថិតនៅចម្ងាយប្រមាណ ៧០គីឡូម៉ែត្រពីទីរួមខេត្តកណ្តាល។ ដោយបានមើលឃើញពីផលលំបាករបស់សិស្សានុសិស្សនៅក្នុងសហគមន៍ ក្នុងការធ្វើដំណើរមកកាន់ទីរួមខេត្ត ដើម្បីស្វះស្វែងរកសៀវភៅអានទើប ក្រុមការងារយើងខ្ញុំបានរួមគ្នាសរសេរជាគម្រោងនេះឡើង ដើម្បីស្វែងរកជំនួយឧបត្ថម្ភដល់ការសាងសង់បណ្ណាល័យសហគមន៍នេះឡើង។

## II. ការរៀបចំផែនការគម្រោង

### ១.គោលបំណង

ដើម្បីជម្រុញឲ្យសិស្សានុសិស្សស្រលាញ់ការអានសៀវភៅ។

### ២.គោលដៅ

ដើម្បីឱ្យគោលបំណងបានសម្រេច និងទទួលបានជោគជ័យ ត្រូវមានគោលដៅចំនួនបី ដូចខាងក្រោម៖

**គោលដៅទី១៖** រៀបចំក្រុមការងារចុះសិក្សាស្ថានភាពជាក់ស្តែងនៅទីតាំង និងកំណត់អំពីទំហំបណ្ណាល័យ និងវេលា ព្រមទាំងគិតគូដល់ការចំណាយ នៅសប្តាហ៍ទី១ ខែមិនា ឆ្នាំ២០២៤

**គោលដៅទី២៖** ការសាងសង់បណ្ណាល័យសហគមន៍សម្រាប់ភូមិ សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៤

**គោលដៅទី៣៖** ការដាក់សម្ភោធដាក់ឱ្យប្រើប្រាស់ ណែនាំ លើកទឹកចិត្តដល់សិស្ស និងប្រជាពលរដ្ឋក្នុងមូលដ្ឋានពីសារៈសំខាន់នៃបណ្ណាល័យ។ សប្ដាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤

## ៣.សកម្មភាព

ដើម្បីសម្រេចបាននូវគោលដៅនៃគម្រោងនេះ បានដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

**គោលដៅទី១៖** រៀបចំក្រុមការងារចុះសិក្សាស្ថានភាពជាក់ស្ដែងអំពីទីតាំង កំណត់អំពីទំហំនៃបណ្ណាល័យនិងពេលវេលាព្រមទាំងគិតគូដល់ការចំណាយនៅសប្ដាហ៍ទី១

- **សកម្មភាព១.១៖** រៀបចំក្រុមការងារមានសមាជិកចំនួន ៦រូប ដើម្បីធ្វើការសិក្សាពីទីតាំង នៅសប្ដាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៤
- **សកម្មភាព១.២៖** ចុះសិក្សាស្ថានភាពទីតាំងនៅដើមសប្ដាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៤
- **សកម្មភាព១.៣៖** លើកគម្រោងចំណាយជូនដល់អ្នកពាក់ព័ន្ធ សប្ដាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៤

**គោលដៅទី២៖** ការសាងសង់បណ្ណាល័យសហគមន៍សម្រាប់ភូមិឱ្យបានរួចរាល់នៅសប្ដាហ៍ទី២

- **សកម្មភាព២.១៖** ធ្វើការសិក្សាលើតម្លៃម៉ៅការ និងសម្រេចជ្រើសយកក្រុមម៉ៅការសំណង់ណាមួយនៅសប្ដាហ៍ទី១ សប្ដាហ៍ទី១ ខែកក្កដា ឆ្នាំ២០២៤
- **សកម្មភាព២.២៖** ស្វែងរកការចូលរួម ការគាំទ្រពីប្រជាពលរដ្ឋ និងសហគមន៍នៅក្នុងសប្ដាហ៍ទី១ ខែកក្កដា ឆ្នាំ២០២៤
- **សកម្មភាព២.៣៖** សាងសង់បណ្ណាល័យ នៅសប្ដាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៤

**គោលដៅទី៣៖** ការដាក់សម្ភោធដាក់ឱ្យប្រើប្រាស់ ណែនាំ លើកទឹកចិត្តដល់សិស្ស និងប្រជាពលរដ្ឋក្នុងនៅមូលដ្ឋានពីសារៈសំខាន់នៃបណ្ណាល័យ។

- **សកម្មភាព៣.១៖** ការដាក់ដំណើការប្រើប្រាស់ សប្ដាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤
- **សកម្មភាព៣.២៖** ការផ្សព្វផ្សាយដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋក្នុងសហគមន៍ចាប់ពីសប្ដាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤
- **សកម្មភាពទី៣.៣៖** ប្រកួតប្រជែងការអានយករង្វាន់ជាប្រចាំ
- **សកម្មភាពទី៣.៤៖** បើកឲ្យសិស្សានុសិស្សខ្ចីសៀវភៅជាប្រចាំ

## ៤.ថវិកាសមិទ្ធកម្ម

ប្រភពថវិកា ដើម្បីគាំទ្រគម្រោងនេះ គឺបានពីជំនួយរបស់ដៃគូរសហការរួមមាន៖

**គោលដៅទី១៖** រៀបចំក្រុមការងារចុះសិក្សាស្ថានភាពជាក់ស្ដែងនៅទីតាំង និងកំណត់អំពីទំហំបណ្ណាល័យនិងវេលា ព្រមទាំងគិតគូដល់ការចំណាយនៅសប្ដាហ៍ទី១ ខែមីនា ឆ្នាំ២០២៤ ចំណាយទឹកប្រាក់អស់ចំនួន ១.០០០.០០០រៀល សម្រាប់ការចំណាយលើការងារនេះដោយទទួលបាន ការឧបត្ថម្ភពីសប្បុរសជនចំនួន ១.៥០០.០០០រៀល។

**គោលដៅទី២៖** ការសាងសង់បណ្ណាល័យសហគមន៍សម្រាប់ភូមិ សប្ដាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៤ ចំណាយទឹកប្រាក់អស់ចំនួន ៣០.៧២៣.៨០០រៀល សម្រាប់ការចំណាយនេះទទួលបានការឧបត្ថម្ភពីមន្ទីរអប់រំយុវជន និងកីឡាខេត្តកណ្ដាលចំនួន ៣១.០០០.០០០រៀល។

**គោលដៅទី៣៖** ការដាក់សម្ពោធដាក់ឱ្យប្រើប្រាស់ ណែនាំ លើកទឹកចិត្តដល់សិស្ស និងប្រជាពលរដ្ឋក្នុងមូលដ្ឋានពីសារៈសំខាន់នៃបណ្ណាល័យ។ សប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤ ចំណាយអស់ ៥.៧៧៦.២០០រៀល សម្រាប់ការចំណាយនេះទទួលបានការឧបត្ថម្ភពី NGO ចំនួន ៥.០០០.០០០រៀល ជាមួយលុយដែលនៅសល់ពីការចំណាយគោលដៅទី១ និងទី២ ទៀតសរុបជារួម ៥.៧៧៦.២០០រៀល។

## ៥.អ្នកទទួលខុសត្រូវ

សមាសភាពអ្នកទទួលខុសត្រូវមានដូចជា៖

**គោលដៅទី១៖**

**សកម្មភាព១.១៖** ធ្វើការរៀបចំជ្រើសរើស និងបង្កើតក្រុមការងារដើម្បីចុះសិក្សាស្ថានភាពទីតាំងជាក់ស្តែងនៅសប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៤

អ្នកទទួលខុសត្រូវ១.១៖លោកស្រី យ៉ាន ដារីយ៉ា។

**សកម្មភាព១.២៖** ចុះសិក្សាស្ថានភាពទីតាំងជាក់ស្តែងនៅសប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៤

អ្នកទទួលខុសត្រូវ ១.២៖ លោក ខឹម ប៊ុនហាក់។

**សកម្មភាព១.៣៖** លើកគម្រោងចំណាយថវិកាជូនម្ចាស់ជំនួយនៅសប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៤

អ្នកទទួលខុសត្រូវ១.៣៖ លោក យ៉ែម រិន។

**គោលដៅទី២៖**

**សកម្មភាព២.១៖** ធ្វើការស្ទាបស្ទង់តម្លៃម៉ៅការសាងសង់ និងជ្រើសយកអ្នកម៉ៅការសាងសង់ សប្តាហ៍ទី១ ខែកក្កដា ឆ្នាំ២០២៤

អ្នកទទួលខុសត្រូវ ២.១៖ លោក យឿន ចើត។

**សកម្មភាព២.២៖** ធ្វើការស្វែងរកការចូលរួមពីសហគមន៍ក្នុងការសាងសង់បណ្ណាល័យសហគមន៍ នៅសប្តាហ៍ទី១ ខែកក្កដា ឆ្នាំ២០២៤

អ្នកទទួលខុសត្រូវ ២.២៖ លោក ទូច កញ្ញា។

**សកម្មភាព២.៣៖** សាងសង់បណ្ណាល័យសហគមន៍ នៅសប្តាហ៍ទី២ នៃខែមិថុនា ឆ្នាំ២០២៤ រហូតដល់សប្តាហ៍ទី២ នៃខែកញ្ញា ឆ្នាំ២០២៤

អ្នកទទួលខុសត្រូវ ២.៣៖ លោក កែម សុវណ្ណ។

**គោលដៅទី៣៖**

**សកម្មភាព៣.១៖** ការដាក់ឱ្យប្រើប្រាស់ណែនាំនិងជម្រុញសិស្សានិសិស្ស ប្រជាពលរដ្ឋក្នុងសហគមន៍ចូលអាន និងអភិរក្សបណ្ណាល័យនៅសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤ នេះតទៅ

អ្នកទទួលខុសត្រូវ ៣.១៖ លោក ចាន់ ធារី

**សកម្មភាព៣.២៖** ផ្សព្វផ្សាយដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋក្នុងសហគមន៍ចាប់ពីសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤ តទៅ

អ្នកទទួលខុសត្រូវ ៣.២៖ លោក ប៊ិន ម៉េងលាង។

**សកម្មភាព៣.៣៖** ការប្រារព្ធពិធីប្រកួតប្រជែងការអានយករង្វាន់នៅសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៤

អ្នកទទួលខុសត្រូវដោយ៣.៣ ដោយលោកស្រី ជួន អមរា។

**សកម្មភាព៣.៤៖** ការប្រារព្ធពិធីប្រកួតប្រជែងការអានយករង្វាន់នៅសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៖ អ្នកទទួលខុសត្រូវដោយ៣.៣ ដោយលោកស្រី ដួន អមរា។

## ៦.សូចនាករ

ដើម្បីផ្ទៀងផ្ទាត់នូវការអនុវត្តសកម្មភាពនីមួយៗ យើងបានកំណត់នូវសូចនាករដូចខាងក្រោម៖

❖ **គោលដៅទី១៖** រៀបចំក្រុមការងារចុះសិក្សាស្ថានភាពទីតាំង កំណត់ពេលវេលា និងលើកគម្រោងចំណាយឱ្យហើយមុនដំណាច់សប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៤

**សកម្មភាព១.១៖** រៀបចំក្រុមការងារមានសមាជិកចំនួន៨នាក់ ដើម្បីចុះសិក្សាពីទីតាំងឱ្យបានមុនដំណាច់សប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៤។

**សូចនាករ១.១៖** ក្រុមការងារចំនួន ៨នាក់ បានចុះទៅសិក្សា និងវាយតម្លៃទីតាំង នៅសប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៤។

**សកម្មភាព១.២៖** ចុះសិក្សាស្ថានភាពអំពីទីតាំងចាប់ពីដើមសប្តាហ៍ទី១ ដល់ដើមសប្តាហ៍ទី៤ ខែមិថុនា ឆ្នាំ ២០២៤។

**សូចនាករ១.២៖** ទីតាំងសម្រាប់ការសាងសង់បណ្ណាល័យត្រូវបានពិនិត្យ និងសម្រេចយកយ៉ាងយូរត្រឹមចុងសប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៤។

**សកម្មភាព១.៣៖** ការលើកជូនគម្រោងចំណាយថវិកាជូនម្ចាស់ជំនួយ នៅចុងសប្តាហ៍ទី១ នៃខែមិថុនា ឆ្នាំ ២០២៤។

**សូចនាករ១.៣៖** គម្រោងចំណាយថវិកាត្រូវបានម្ចាស់ជំនួយពិនិត្យ និងសម្រេចយ៉ាងយូរនៅត្រឹមសប្តាហ៍ទី៤ ខែមិថុនា ឆ្នាំ២០២៤។

❖ **គោលដៅទី២៖** ការសាងសង់បណ្ណាល័យសហគមន៍សម្រាប់ភូមិត្រូវធ្វើឱ្យហើយមុនដំណាច់សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៤

**សកម្មភាព២.១៖** ធ្វើការស្ទង់តម្លៃម៉ៅការសាងសង់ និងជ្រើសរើស អ្នកម៉ៅការសាងសង់នៅសប្តាហ៍ទី១ ខែកក្កដា ឆ្នាំ២០២៤។

**សូចនាករ២.១៖** តម្លៃម៉ៅការសំណង់ត្រូវបានស្ទង់រួចរាល់ និងអ្នកម៉ៅការសាងសង់ត្រូវបានជ្រើសរើសមុនដំណាច់សប្តាហ៍ទី១ ខែកក្កដា ឆ្នាំ២០២៤។

**សកម្មភាព២.២៖** ស្វែងរកការចូលរួមពីសហគមន៍ក្នុងការសាងសង់បណ្ណាល័យសហគមន៍ ធ្វើឡើងចាប់ពីសប្តាហ៍ទី១ ដល់ថ្ងៃសប្តាហ៍ទី២ ខែកក្កដា ឆ្នាំ២០២៤។

**សូចនាករ២.២៖** អ្នកស្ម័គ្រចិត្ត មួយក្រុមក្នុងសហគមន៍ បានស្ម័គ្រចិត្តចូលរួម ក្នុងដំណើរនៃការសាងសង់បណ្ណាល័យសហគមន៍។

**សកម្មភាព ២.៣៖** សាងសង់បណ្ណាល័យសហគមន៍ ចាប់ពីសប្តាហ៍ទី២ ខែមិថុនា រហូតដល់សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៤។

**សូចនាករ ២.៣៖** បណ្ណាល័យសហគមន៍ចំនួន ១ខ្នង ដែលមានបណ្តោយ ១៥ម៉ែត្រ ទទឹង ៨ម៉ែត្រ និងកម្ពស់ ៦,៥ម៉ែត្រ (ចាក់សាប រៀបឥដ្ឋពាក់កណ្តាល បូក លាបថ្នាំ និងប្រក់ដំបូលស័ង្កសី) ត្រូវបានសាងសង់រួចរាល់នៅសប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៤។

- **គោលដៅទី៣៖** ការដាក់ឱ្យប្រើប្រាស់ និងធ្វើការផ្សព្វផ្សាយឱ្យសិស្សានុសិស្សប្រជាពលរដ្ឋក្នុងសហគមន៍ចូលអាន ចាប់ផ្តើមពីសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤ នេះតទៅ។
  - **សកម្មភាព៣.១៖** សម្ពោធដាក់ឱ្យប្រើប្រាស់ ណែនាំ ដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋក្នុងសហគមន៍ចូលអាន និងអភិរក្សបណ្ណាល័យ នៅសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤។
  - **សូចនាករ៣.១៖** សិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងភូមិសីងមានបណ្ណាល័យក្នុងសហគមន៍សម្រាប់ចូលអាន ឬ ខ្ចីសៀវភៅចាប់ពីសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤ តទៅ។
  - **សកម្មភាព៣.២៖** ផ្សព្វផ្សាយដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងសហគមន៍ ចាប់ពីសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤ តទៅ។
  - **សូចនាករ៣.២៖** សិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងសហគមន៍បានទទួលការណែនាំផ្សព្វផ្សាយតាមថ្ងៃ ដែលបានកំណត់ដើម្បីយល់ដឹងពីសារៈសំខាន់នៃការអានសៀវភៅ។

## ៧.មធ្យោបាយផ្ទៀងផ្ទាត់

ដើម្បីផ្ទៀងផ្ទាត់លទ្ធផលសកម្មភាពនីមួយៗយើងបានកំណត់នូវមធ្យោបាយផ្ទៀងផ្ទាត់ដូចខាងក្រោម៖

- **គោលដៅទី១៖** ការរៀបចំក្រុមការងារចុះធ្វើសិក្សាស្ថានភាពទីតាំង កំណត់ពេលវេលា និងការលើកគម្រោងចំណាយឱ្យហើយមុនដំណាច់សប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៤។

  **សកម្មភាព១.១៖** រៀបចំក្រុមការងារដែលមានសមាជិកចំនួន ៨នាក់ ដើម្បីចុះសិក្សាជាក់ស្តែងឱ្យបានមុនដំណាច់សប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៤។

  **មធ្យោបាយផ្ទៀងផ្ទាត់១.១៖** តារាងបញ្ជីឈ្មោះក្រុមការងារចំនួន៨នាក់។

  **សកម្មភាព១.២៖** ការចុះសិក្សាស្ថានភាពទីតាំងជាក់ស្តែងចាប់ពីថ្ងៃទី០១ រហូតដល់សប្តាហ៍ទី៤ ខែមិថុនា ឆ្នាំ២០២៤។

  **មធ្យោបាយផ្ទៀងផ្ទាត់ ១.២៖** របាយការណ៍ស្តីពីការចុះសិក្សាស្ថានភាពទីតាំងជាក់ស្តែង។

  **សកម្មភាព១.៣៖** ការលើកគម្រោងចំណាយថវិកាជូនដល់ម្ចាស់ជំនួយ នៅចុងសប្តាហ៍ទី១ នៃខែមិថុនា ឆ្នាំ ២០២៤។

  **មធ្យោបាយផ្ទៀងផ្ទាត់ ១.៣៖** តារាងបញ្ជីចំណាយថវិកា។

- **គោលដៅទី២៖** ការសាងសង់បណ្ណាល័យសហគមន៍សម្រាប់ភូមិ ធ្វើឱ្យហើយមុនដំណាច់សប្តាហ៍ទី២ ខែកក្កដា ឆ្នាំ២០២៤

  **សកម្មភាព២.១៖** ធ្វើការស្នង់តម្លៃម៉ៅការសាងសង់ និងធ្វើការជ្រើសរើសអ្នកម៉ៅការសាងសង់នៅសប្តាហ៍ទី១ ខែកក្កដា ឆ្នាំ២០២៤។

  **មធ្យោបាយផ្ទៀងផ្ទាត់២.១៖** ពាក្យស្នើសុំសាងសង់របស់អ្នកម៉ៅការ និងកិច្ចសន្យាសាងសង់រវាងអ្នកគ្រប់គ្រងគម្រោង និងអ្នកម៉ៅការសាងសង់។

  **សកម្មភាព២.២៖** ស្វែងរកការចូលរួមពីសហគមន៍ក្នុងការសាងសង់បណ្ណាល័យសហគមន៍ ចាប់ពីសប្តាហ៍ទី១ ដល់ថ្ងៃសប្តាហ៍ទី២ ខែកក្កដា ឆ្នាំ២០២៤។

  **មធ្យោបាយផ្ទៀងផ្ទាត់ ២.២៖** បញ្ជីឈ្មោះអ្នកស្ម័គ្រចិត្តក្នុងសហគមន៍។

**សកម្មភាព២.៣៖** សាងសង់បណ្ណាល័យសហគមន៍ ចាប់ពីសប្តាហ៍ទី២ ខែមិថុនា ដល់សប្តាហ៍ទី២ ខែកក្កដា ឆ្នាំ២០២៤។

**មធ្យោបាយផ្ទៀងផ្ទាត់២.៣៖** ការសាងសង់ធ្វើឱ្យបានត្រឹមត្រូវទៅតាមប្លង់ដែលបានកំណត់របាយការណ៍ស្តីពីការបញ្ចប់ការសាងសង់

- **គោលដៅទី៣៖** ការដាក់ឱ្យប្រើប្រាស់ និងផ្សព្វផ្សាយឱ្យសិស្សានុសិស្សប្រជាពលរដ្ឋក្នុងសហគមន៍ចូលអាន ចាប់ផ្តើមពីសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤ នេះតទៅ។

**សកម្មភាព៣.១៖** សម្ពោធដាក់ឱ្យប្រើប្រាស់ ណែនាំ ដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋក្នុងសហគមន៍ចូលអាន និងអភិរក្សបណ្ណាល័យ នៅសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤។

**មធ្យោបាយផ្ទៀងផ្ទាត់ ៣.១៖** របាយការណ៍ស្តីពីការដាក់ឱ្យប្រើប្រាស់បណ្ណាល័យ

**សកម្មភាព៣.២៖** ផ្សព្វផ្សាយដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងសហគមន៍ ចាប់ពីសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤ តទៅ។

**មធ្យោបាយផ្ទៀងផ្ទាត់ ៣.២៖** បញ្ជីវត្តមានអ្នកចូលរួមចាប់ពីសប្តាហ៍ទី៣ ខែកក្កដា ឆ្នាំ២០២៤។

## ៨.ហានិភ័យ

បើទោះបីជា យើងបានកំណត់នូវសកម្មភាពទៅតាមគម្រោងដែលបានគ្រោងទុកក៏ដោយ ក៏យើងបានកំណត់នូវហានិភ័យដែលអាចកើតមានឡើងដែលនឹងអាចធ្វើឱ្យគម្រោងរបស់យើងមិនសម្រេចជោគជ័យទៅបានដូចខាងក្រោម៖

- **គោលដៅទី១៖** ការរៀបចំក្រុមការងារចុះសិក្សាស្ថានភាពទីតាំង កំណត់ពេលវេលា និងលើកគម្រោងចំណាយធនធាន ថវិកា ឧបករណ៍-សម្ភារៈឱ្យហើយនៅសប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៤។

**សកម្មភាព១.១៖** រៀបចំក្រុមការងារមានសមាជិកចំនួន ៨នាក់ ដើម្បីចុះសិក្សាជាក់ស្តែងឱ្យបានមុនដំណាច់សប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៤។

**ហានិភ័យ ១.១៖** អាជ្ញាធរមូលដ្ឋានមិនសូវសហការជាមួយក្រុមការងារ។

**សកម្មភាព១.២៖** ចុះសិក្សាស្ថានភាពទីតាំងជាក់ស្តែងចាប់ពីដើមសប្តាហ៍ទី១ រហូតដល់សប្តាហ៍ទី៤ ខែមិថុនា ឆ្នាំ២០២៤។

**ហានិភ័យ ១.២៖** ក្រុមការងារមិនអាចចុះទៅសិក្សាស្ថានភាពទីតាំងជាក់ស្តែងដោយអាជ្ញាធរមូលដ្ឋានមិនសូវចូលរួមសហការជាមួយក្រុមការងារបានជិតដល់។

**សកម្មភាព១.៣៖** ការលើកគម្រោងចំណាយថវិកាជូនម្ចាស់គម្រោងយ៉ាងយូរនៅសប្តាហ៍ទី១ ខែមិថុនា ឆ្នាំ ២០២៤។

**ហានិភ័យ ១.៣៖** ម្ចាស់គម្រោងពុំឋកភាពលើគម្រោងចំណាយថវិកា។

- **គោលដៅទី២៖** ការសាងសង់បណ្ណាល័យសហគមន៍សម្រាប់ភូមិ និងត្រូវឱ្យហើយមុនសប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ ២០២៤

**សកម្មភាព២.១៖** ធ្វើការស្វែងតម្លៃម៉ៅការសាងសង់ និងជ្រើសយកអ្នកម៉ៅការសាងសង់ ធ្វើឡើងនៅសប្តាហ៍ទី១ ខែកក្កដា ឆ្នាំ២០២៤។

**ហានិភ័យ២.១៖** ពុំមានអ្នកម៉ៅការដោយហេតុថា ទីតាំងមានចំងាយផ្លូវឆ្ងាយនិងលំបាក ពិបាកក្នុងការដឹកជញ្ជូនសម្ភារៈសម្រាប់ការសាងសង់។

**សកម្មភាព២.២៖** ស្វែងរកការចូលរួមពីសហគមន៍ក្នុងការសាងសង់បណ្ណាល័យសហគមន៍ ចាប់ពីសប្តាហ៍ទី១ រហូតដល់សប្តាហ៍ទី២ ខែកក្កដា ឆ្នាំ២០២៤។

**ហានិភ័យ២.២៖** មិនមានការចូលរួមពីអ្នកស្ម័គ្រចិត្តក្នុងសហគមន៍។

**សកម្មភាព២.៣៖** សាងសង់បណ្ណាល័យសហគមន៍ ចាប់ពីសប្តាហ៍ទី២ ខែកក្កដា ដល់សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៤។

**ហានិភ័យ២.៣៖** ការសាងសង់មានភាពយឺតយ៉ាវ មិនអាចសាងសង់មិនរួចរាល់មុនថ្ងៃដែលបានកំណត់ ដោយសារខ្វះកម្មករជំនាញ។

- **គោលដៅទី៣៖** ការដាក់ឱ្យប្រើប្រាស់ និងផ្សព្វផ្សាយឱ្យសិស្សានុសិស្សប្រជាពលរដ្ឋក្នុងសហគមន៍ចូលអាន ចាប់ផ្តើមពីសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤ នេះតទៅ។

**សកម្មភាព៣.១៖** សម្ពោធដាក់ឱ្យប្រើប្រាស់ និងណែនាំ ដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋក្នុងសហគមន៍ ចូលអាន និងអភិរក្សបណ្ណាល័យ នៅសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤។

**ហានិភ័យ៣.១៖** ពុំមានអ្នកធ្វើជាបណ្ណារក្ស កង្វះការថែទាំបន្ទាប់ពីការដាក់ ពុំមានអ្នកចូលអានសៀវភៅ ឬខ្ចីសៀវភៅពីបណ្ណាល័យសហគមន៍។

**សកម្មភាព៣.២** ធ្វើការផ្សព្វផ្សាយដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងសហគមន៍ ចាប់ពីសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០២៤ តទៅ។

**ហានិភ័យ៣.២៖** ពុំមានអ្នកមកចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយ។

## III. ដំណើរការគម្រោង

## ១- ការកំណត់ប្រភពថវិកា

ប្រភពថវិកា ដើម្បីធ្វើការគាំទ្រគម្រោងនេះគឺបានមកពីជំនួយរបស់អង្គការជីវិតថ្លៃថ្នូ(LWD) មន្ទីរ អប់រំ យុវជន និងកីឡា ព្រមទាំងថវិកាដែលបានពីការឧបត្ថម្ភប្រជានជនរស់នៅក្នុងសហគមន៍។(ក្នុងឧបសម្ព័ន្ធទី១)

## ២- ការជ្រើសរើសធនធានមនុស្ស

ក្រុមការងារចំនួន០៨នាក់ ត្រូវបានជ្រើសរើសចេញពីប្រធានការិយាល័យអប់រំស្រុកចំនួន១រូប មន្ត្រី អប់រំ ស្រុកចំនួន៣រូប នាយិកាសាលាបឋមសិក្សាដូងចំនួន១រូប គ្រូបង្រៀនចំនួន១រូប មេភូមិចំនួន១រូប និងតំណាងសហគមន៍ចំនួន១រូប ដោយបានធ្វើការបែងចែកការទទួលខុសត្រូវរៀងៗខ្លួន។

## ៣- ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង

### ក- រចនាសម្ព័ន្ធគ្រប់គ្រង



## ខ- ទំនួលខុសត្រូវ

ក្រុមការងារចំនួន ៨នាក់ បានធ្វើការបែងចែងតួនាទី និងភារកិច្ចទទួលខុសត្រូវដូចខាងក្រោមៈ

| ល.រ | គោត្តនាម និងនាម | តួនាទី | | ការទទួលខុសត្រូវ |
|---|---|---|---|---|
| ១ | លោក **វេតនា តារា** | ប្រធានការិយាល័យអប់រំស្រុក | ប្រធានគម្រោង | រៀបចំបង្កើតក្រុមការងាររៀបចំក្រុមការងារចុះសិក្សាស្ថានភាពទីតាំងនិងបែងចែកតួនាទី និងភារកិច្ច រៀបចំបញ្ជីឈ្មោះក្រុមការងារប្រគល់អគារក្រោយបញ្ចប់ការសាងសង់ |
| ២ | លោក **រ៉ុន សីហៈ** | តំណាងភូមិ/ឃុំ | អនុប្រធានគម្រោង | ចុះសិក្សាស្ថានភាពទីតាំង<br>រៀបចំរបាយការណ៍អំពីលទ្ធផលចុះសិក្សាស្ថានភាពទីតាំង |
| ៣ | លោក **យ៉ាន ដារីយ៉ា** | គណនេយ្យ | គណនេយ្យករ | លើកគម្រោងចំណាយថវិការ<br>ពិនិត្យកញ្ចប់ថវិកាដែលបានដែលបានចំណាយ<br>រៀបចំតារាងបញ្ជីចំណាយ |
| ៤ | លោក **យឿន ចើត** | មន្ត្រីការិយាល័យអប់រំស្រុក | មន្ត្រីរដ្ឋបាល | ស្វង់តម្លៃ និងជ្រើសយកអ្នកម៉ៅការសំណង់<br>ពិនិត្យពាក្យស្នើសុំរបស់អ្នកម៉ៅការ<br>រៀបចំកិច្ចសន្យាសាងសង់ |
| ៥ | លោក **ជួន អមរា** | តំណាងសហគមន៍ | អ្នកសម្របសម្រួល | ស្វែងរកការចូលរួមពីសហគមន៍<br>ចូលរួមជ្រើសរើសអ្នកស្ម័គ្រចិត្តក្នុងសហគមន៍<br>រៀបចំបញ្ជីឈ្មោះអ្នកស្ម័គ្រចិត្តក្នុងសហគមន៍ |
| ៦ | លោក **ប៊ិន ម៉េងលាង** | មន្ត្រីការិយាល័យអប់រំស្រុក | មន្ត្រីចុះផ្ទាល់ | ពិនិត្យមើលដំណើរការសាងសង់ តើត្រូវតាមប្លង់ និង ពេលវេលាដែលបានកំណត់ឬទេ ?<br>រៀបចំរបាយការណ៍ស្ដីពីការបញ្ចប់ការសាងសង់ |
| ៧ | លោក **ខឹម ប៊ុនហាក់** | នាយកសាលា | អ្នកសម្របសម្រួល | សម្របសម្រួលទីតាំងក្នុងការប្រគល់ទទួលដាក់ឱ្យប្រើប្រាស់បណ្ណាល័យសហគមន៍<br>រៀបចំរបាយការណ៍ស្ដីពីការចូលអាន ឬខ្ចី |
| ៨ | លោក យ៉ែម រិន | គ្រូបង្រៀន | អ្នកសម្របសម្រួល | សម្របសម្រួលទីតាំងសម្រាប់ធ្វើការផ្សព្វផ្សាយរៀបចំបញ្ជីវត្តមានអ្នកចូលរួម |

ក្រុមការងារយើងខ្ញុំ ចំនួនទាំង៨នាក់ស្ម័គ្រចិត្តចូលរួមក្នុងការលើកកម្ពស់ស្មារតីសិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងសហគមន៍ឱ្យនិយមស្រលាញ់ការអានដើម្បីចូលរួមចំណែកលុបបំបាត់អនក្ខរកម្មភាព និងដើម្បីឆ្លើយតបទៅនឹងទិវាអំណានថ្ងៃទី១១ ខែមីនា( ជារៀងរាល់ឆ្នាំ )។

## ៤- ការប្រើប្រាស់ផែនការពេលវេលា

គម្រោងនេះ ត្រូវចំណាយពេលវេលាសម្រាប់ ការអនុវត្តរយៈពេល ១១៥ថ្ងៃ ក្នុងនោះសកម្មភាពទី១ ត្រូវមានរយៈពេល៣០ថ្ងៃ ចំណែកសកម្មភាពទី២ ត្រូវមានរយៈពេល៧២ថ្ងៃ និងសកម្មភាពទី៣ មានរយៈពេល៧ថ្ងៃ។

| ល.រ | ផែនការសកម្មភាព | ចំនួនថ្ងៃ | ថ្ងៃចាប់ផ្តើម | ថ្ងៃបញ្ចប់ | ខែមិថុនា ឆ្នាំ២០២៤ | | | | ខែកក្កដា ឆ្នាំ២០២៤ | | | | ខែសីហា ឆ្នាំ២០២៤ | | | | ខែកញ្ញា ឆ្នាំ២០២៤ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | សប្តាហ៍ | | | | សប្តាហ៍ | | | | សប្តាហ៍ | | | | សប្តាហ៍ | | | |
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១ | រៀបចំក្រុមការងារចុះសិក្សាស្ថានភាព ទីតាំង កំណត់ពេលវេលានិង លើកគម្រោងចំណាយឱ្យហើយមុន ដំណាច់ខែមិថុនា ឆ្នាំ២០២៤ | ៣០ | ១/៦/២០២៤ | ៣០/៦/២០២៤ | | | | | | | | | | | | | | | | |
| ១.១ | រៀបចំក្រុមការងារមានសមាជិក ចំនួន៨នាក់ ដើម្បីចុះសិក្សាពីទី តាំងឱ្យបានមុនថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៤ | ៧ | ១/៦/២០២៤ | ៧/៦/២០២៤ | | | | | | | | | | | | | | | | |
| ១.២ | ចុះសិក្សាស្ថានភាពទីតាំងចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤ | ៨ | ១១/៦/២០២៤ | ១៨/៦/២០២៤ | | | | | | | | | | | | | | | | |
| ១.៣ | លើកគម្រោងចំណាយថវិកាជូនម្ចាស់ជំនួយ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ | ១១ | ១៩/៦/២០២៤ | ៣០/៦/២០២៤ | | | | | | | | | | | | | | | | |
| ២ | ធ្វើការស្ទង់តម្លៃម៉ៅការសាងសង់ និងជ្រើសយកអ្នកម៉ៅការសាងសង់ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ | ១០ | ១/៧/២០២៤ | ១០/៧/២០២៤ | | | | | | | | | | | | | | | | |
| ២.១ | ការសាងសង់បណ្ណាល័យសហគមន៍សម្រាប់ភូមិដូងឱ្យហើយមុនថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤ | ៧២ | ១/៧/២០១៤ | ១២/៩/២០២៤ | | | | | | | | | | | | | | | | |
| ២.២ | ស្វែងរកការចូលរួមពីសហគមន៍ក្នុងការសាងសង់បណ្ណាល័យសហគមន៍ចាប់ពីថ្ងៃទី១ រហូតដល់ថ្ងៃទី១០ 90 ខែកក្កដា ឆ្នាំ២០២៤ | ១០ | ១/៧/២០២៤ | ១០/៧/២០២៤ | | | | | | | | | | | | | | | | |
| ២.៣ | សាងសង់បណ្ណាល័យសហគមន៍នៅភូមិដូង ចាប់ពីថ្ងៃទី៨ខែកក្កដាដល់ថ្ងៃទី១២ខែកក្កដាឆ្នាំ២០២៤ | ៦៥ | ៨/៧/២០២៤ | ១២/៩/២០២៤ | | | | | | | | | | | | | | | | |
| ៣ | ការដាក់ឱ្យប្រើប្រាស់និងផ្សព្វផ្សាយឱ្យសិស្សានុ-សិស្ស និងប្រជាពលរដ្ឋក្នុងសហគមន៍ចូលអានចាប់ពីសប្តាហ៍ទី៣ នៃខែកញ្ញា ឆ្នាំ២០២៤ | ៤ | ១៧/៩/២០២៤ | ២០/៩/២០២៤ | | | | | | | | | | | | | | | | |
| ៣.១ | ការដាក់ឱ្យប្រើប្រាស់បណ្ណាល័យសហគមន៍ចាប់ពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤នេះតទៅ | ៥ | ១៧/៩/២០២៤ | ២២/៩/២០២៤ | | | | | | | | | | | | | | | | |
| ៣.២ | ធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ក្នុងសហគមន៍ ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៤ | ៥ | ១៧/៩/២០២៤ | ២២/៩/២០២៤ | | | | | | | | | | | | | | | | |

## ៥- ការប្រើប្រាស់ធនធានរបស់គម្រោង

ដើម្បីចូលរួមចំណែកក្នុងការជំរុញការអានសៀវភៅនៅក្នុងសហគមន៍ ក្រុមយើងខ្ញុំបានរួមគ្នាសរសេរជាគម្រោងនេះឡើង ដោយបានជំនួយមកពីអង្គការជីវិតថ្លៃថ្នូ(LWD) មន្ទីរអប់រំ យុវជន និងកីឡា និងអង្គការ អន្តរជាតិស្ទីសព្រមទាំងមានការចូលរួមពីសហគមន៍ជាកម្លាំងក្នុងការសាងសង់បណ្ណាល័យសហគមន៍សម្រាប់ភូមិព្រែកជ្រៃ។ ដើម្បីផ្សារភ្ជាប់ស្មារតីសាមគ្គីភាព ដោយចំណាយថវិកាសរុបរួមចំនួន៣៧ ០២៣ ៨០០រៀល ដោយរួមមានថ្លៃឧបករណ៍-សម្ភារៈចំនួន៣០ ២២៣ ៨០០រៀល និងថ្លៃពលកម្មចំនួន៦ ៨០០ ០០០រៀល។

| ល.រ. | បរិយាយ | ឯកតា | បរិមាណ | តម្លៃឯកតា (៛) | តម្លៃសរុប(៛) | ផ្សេងៗ |
|---|---|---|---|---|---|---|
| I | ឧបករណ៍-សម្ភារៈ | | | | | |
| ១ | ឥដ្ឋតាន់ | ដុំ | ៣០០០ | ១៥០ | ៤៥០,០០០ | |
| ២ | ឥដ្ឋប្រហោង | ដុំ | ២៥០០ | ១២០ | | |
| ៣ | ខ្សាច់ ((គ្រើម + ម៉ត់) | ម៣ | ១៣ | ៤២,៧៥០ | ៥៥៥,៧៥០ | |
| ៤ | ដែកកង ៦លី (៨០កង) | តោន | ១.៥ | ៨២០,០០០ | ១,២៣០,០០០ | |
| ៥ | ដែក ១៤លី (៣៦ដើម) | តោន | ៤ | ២,៨៦៤,០០០ | ១១,៤៥៦,០០០ | |
| ៦ | ថ្ម 1 x 2 | ម៣ | ១៣ | ៨៣,៨៥០ | ១,០៩០,០៥០ | |
| ៧ | ថ្ម 4 x 6 | ម៣ | ១១ | ៥២,០០០ | ៥៧២,០០០ | |
| ៨ | ស៊ីម៉ង់ត៍ | តោន | ៤.៥ | ៤២០,០០០ | ១,៨៩០,០០០ | |
| ៩ | ស័ង្កសី | ម២ | ២០០ | ២៧,៥០០ | ៥,៥០០,០០០ | |
| ១០ | ទ្វារ 2m x 1m | សន្លឹក | ២ | ១,២០០,០០០ | ២,៤០០,០០០ | |
| ១១ | បង្អួច 1.25m x 1m | សន្លឹក | ៦ | ៤១០,០០០ | ២,៤៦០,០០០ | |
| ១២ | ថ្នាំលាប (U-90) | ធុង | ៤ | ៣២០,០០០ | ១,២៨០,០០០ | |
| ១៣ | ថ្លៃដឹកជញ្ជូន | លើក | ២ | ៥២០,០០០ | ១,០៤០,០០០ | |
| | | | | តម្លៃសរុប(I)៖ | ៣០,២២៣,៨០០ | |
| II | ពលកម្ម | | | | | |
| ១ | តម្លៃពលកម្ម | អគារ | ១ | ៦,៨០០,០០០ | ៦,៨០០,០០០ | |
| | | | | តម្លៃសរុប(II)៖ | ៦,៨០០,០០០ | |
| | | | | សរុបថវិកាចំណាយរួម(I+II)៖ | ៣៧,០២៣,៨០០ | |

កំណត់សំគាល់៖ ទឹកប្រាក់សរុបស្មើនឹង ៣៧ ០២៣ ៨០០,០០រៀល(សាមសិបប្រាំពីរលាន ម្ភៃបី ពាន់ និងប្រាំបីរយរៀលគត់)។ (ស្មើនឹង ៩ ០៣០.២០USD អត្រាប្តូរប្រាក់ ១USD = ៤ ១០០KHR)។

## ៦- ការតាមដាន ការវាយតម្លៃ និងត្រួតពិនិត្យគម្រោង

### ៦-១. ការតាមដាន

ប្រធានគម្រោងចាំបាច់ត្រូវប្រើការតាមដានគ្រប់សកម្មភាពនៃដំណើរការចាប់ផ្ដើមអនុវត្តគម្រោង តាំងពីការជ្រើសរើសក្រុមការងារ អ្នកបច្ចេកទេសចុះសិក្សាទីតាំងភូមិសាស្ត្រ សិក្សាតម្លៃ ចំនួនឧបករណ៍-សម្ភារៈ។

ក្នុងដំណាក់កាលសម្រាប់ការអនុវត្តគម្រោង ក្រុមការងារគម្រោងបានរៀបចំមន្ត្រីទទួលបន្ទុកតាមដាន និងត្រួតពិនិត្យ វាយតម្លៃគម្រោង និងតាមដានបន្ត។ ការអនុវត្តការងាររៀងៗខ្លួន ក្នុងគោលបំណងដើម្បី ធានាប្រសិទ្ធិភាពនៃការសាងសង់ ធ្វើរបាយការណ៍ វាយតម្លៃការងារដាក់ជូនម្ចាស់ជំនួយទៅតាមផែនការ។

### ៦-២. ការវាយតម្លៃ

ការវាយតម្លៃគម្រោងត្រូវធ្វើឡើងជាបួនដំណាក់កាល ដោយមានការប្រជុំវាយតម្លៃទៅលើលទ្ធផល គម្រោងសកម្មភាពណាមួយ ដើម្បីថ្លឹងថ្លែងនិងប្រៀបធៀបទៅនឹងលទ្ធផលការងារ ដែលសម្រេចបានថា "តើមានចំណុចណា?" យើងត្រូវកែតម្រូវបន្ថែមតាមរយៈការសួរស្ទាបស្ទង់ទៅលើកម្រិតសម្រេចបាន ដោយយល់ ដឹងពីប្រព័ន្ធផ្សព្វផ្សាយរបស់គម្រោង។ លើសពីនេះទៀត ប្រធានគម្រោងត្រូវធ្វើការវាយតម្លៃចំណុច សំខាន់ៗ ដែលទាក់ទងទៅនឹងគោលបំណងរបស់គម្រោងថា "តើការសាងសង់បណ្ណាគារសហគមន៍ បានសម្រេចដល់ កម្រិតណាហើយ?" ការវាយតម្លៃវឌ្ឍនភាពនៃស្ថានភាពសំណង់នៃការងារសាងសង់ និងការរៀបចំឧបករណ៍-សម្ភារៈ នៅក្នុងបណ្ណាល័យបានជិតសម្រេចជោគជ័យ ១០០% និងត្រូវប្រគល់ទទួលជូនទៅគណៈគ្រប់គ្រង សាលាសហគមន៍ សម្រាប់ប្រើប្រាស់ជាប្រយោជន៍ក្នុងមូលដ្ឋាន ដើម្បីបម្រើទៅតាមសេចក្ដីត្រូវការរបស់ សិស្សានុសិស្ស និងប្រជាពលរដ្ឋឱ្យឆ្លើយតបទៅនឹងចំណេះដឹង និងតាមសម័យកាលឌីជីថល៤.០។

១. Pre-Evaluation គឺកំឡុងពេលសិក្សាស្រាវជ្រាវ និងមុនពេលចាប់ផ្ដើមអនុវត្តគម្រោងសាងសង់។

២. On-going-Evaluation គឺកំឡុងពេលដំណើរការអនុវត្តគម្រោងសាងសង់អាគារបណ្ណាល័យ។

៣. End-Evaluation គឺចុះត្រួតពិនិត្យវាយតម្លៃ ដោយអនុវត្តពេលជិតចប់គម្រោងសាងសង់។

៤. Post-Evaluation គឺដើម្បីកំណត់លទ្ធផលពិតប្រាកដ និងផ្ទៀងផ្ទាត់ដោយ Impact Indicator។

### ៦-៦. ការតាមដានបន្ត

បន្ទាប់ពីបានបញ្ចប់ការសាងសង់រួចរាល់ជោគជ័យ១០០% ទៅតាមគម្រោងដែលបានគ្រោងទុកហើយ បណ្ណាល័យនេះ នឹងត្រូវប្រគល់ជូនទៅគណៈគ្រប់គ្រងសាលា តាមរយៈអ្នកសម្របសម្រួលគម្រោងទៅកាន់ ម្ចាស់ជំនួយវិញ ក្នុងទម្រង់ជារបាយការណ៍ដោយរាយការណ៍ពីសមិទ្ធិផលដែលសម្រេចបាន និងបី(៣)សប្ដាហ៍ ក្រោយ បន្ទាប់ពីការដាក់ឱ្យប្រើប្រាស់ពីវឌ្ឍនភាពនៃស្ថានភាពសំណង់ និងការថែទាំបន្ត។

## ៧- ការបញ្ចប់គម្រោង

ប្រធានអនុវត្តគម្រោងត្រូវរៀបចំលិខិតឯកសារ សម្រាប់ធ្វើការប្រគល់-ទទួល ជាលាយលក្ខណ៍អក្សរ រវាងប្រធានគម្រោង និងនាយកសាលា ដើម្បីបិទបញ្ចប់ការសាងសង់។ រួចដាក់របាយការណ៍បញ្ចប់គម្រោងជូន ទៅម្ចាស់ជំនួយភ្ជាប់ ជាមួយឯកសារពាក់ព័ន្ធ ព្រមទាំងកិច្ចសន្យាអ្នកម៉ៅការសាងសង់ វិក័យបត្រចំណាយ ថវិកា ធនធាន ដូចជាលើការទិញឧបករណ៍-សម្ភារៈ លិខិតប្រគល់-ទទួលអគារ និងរូបថតភ្ជាប់ជាមួយទុកជា ភស្តុតាង។

## IV. **ការវិភាគ** SWOT

| ❖ ចំណុចខ្លាំង | ❖ ចំណុចខ្សោយ |
|---|---|
| -ក្រុមការងារសាមគ្គីគ្នាបានល្អ<br>-ការចូលរួមរបស់ប្រជាពលរដ្ឋយ៉ាងសកម្ម | -ថវិកាមានកម្រិត<br>-ទំហំដីកសាងបណ្ណាល័យតូច |
| **❖ ឱកាស** | **❖ ការគំរាមកំហែង** |
| -មានការគាំទ្រពីក្រសួងអប់រំ<br>-មានការគាំទ្រពី NGO | -អាកាសធាតុប្រែប្រួល<br>-ប្រជាជននៅតំបន់ផ្សេងអន់ចិត្ត |

## V. **សេចក្តីសន្និដ្ឋាន**

សរុបសេចក្តីមក ក្រុមការងាររបស់យើងខ្ញុំសង្ឃឹមថា បណ្ណាល័យសហគមន៍សម្រាប់ភូមិព្រៃកជ្រៃ ដែលនឹងលេចរូបរាងឡើងនាពេលខាងមុខនេះ នឹងចូលរួមចំណែកក្នុងការបណ្តុះស្មារតីសិស្សានុសិស្ស និងប្រជាពលរដ្ឋក្នុងសហគមន៍ឱ្យស្រលាញ់ការអានសៀវភៅបានកាន់តែច្រើនឡើងៗ។ ជាពិសេស គឺកុមារតូចៗ ដោយគាត់អាចទទួលបានចំណេះដឹងថ្មីៗបន្ថែមទៀត តាមរយៈពីការអានសៀវភៅច្រើនប្រភេទ ដែលមាននៅក្នុង បណ្ណាល័យសហគមន៍នេះ។ ជាងនេះទៅទៀត ការបង្កើតបណ្ណាល័យសហមន៍សម្រាប់ភូមិព្រៃកជ្រៃនេះ គឺដើម្បី ឆ្លើយតបទៅនឹងសារាចរណែនាំស្តីពីការប្រារព្ធទិវាជាតិអំនាន ប្រារព្ធធ្វើនៅថ្ងៃទី១១ ខែមីនា (ជារៀងរាល់ឆ្នាំ) របស់រាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១៩។ ការបណ្តុះទម្លាប់នៃអាន ជំរុញវប្បធម៌អាន និងលើក កម្ពស់វប្បធម៌អាន ពិតជាចូលរួមចំណែកយ៉ាងធំ ធេងក្នុងការការពារ និងពង្រឹងវប្បធម៌ អរិយធម៌ខ្មែរយើង។

ក្រុមការងារយើងខ្ញុំ សង្ឃឹមថាភាពជោគជ័យនៃគម្រោងនេះ នឹងបន្តឱ្យមានការអនុវត្តគម្រោងថ្មីៗ បន្ថែមទៀត ដែលចូលរួមចំណែកក្នុងការជួយដល់សហគមន៍។ ជាពិសេសតំបន់ឆ្ងាយៗដាច់ស្រយ៉ា ដើម្បីឱ្យ ពួកគាត់ទទួលបាននូវឱកាសក្នុងការអភិវឌ្ឍនខ្លួន ជាពិសេសចូលរួមចំណែកលុបបំបាត់អនក្ខរកម្ម បោះបង់ការសិក្សា និងភាពគ្មានការងារធ្វើក្នុងសហគមន៍។